# Diaper Rash Information

## ព័ត៌មានអំពីការរលាកកន្ទប

ការរលាកកន្ទបគឺជាពាក្យដែលប្រើសម្រាប់បកស្រាយនូវការឡើងកន្ទួលក្រហាយនៅកន្លែងដែលរុំជិតនៅក្នុងកន្ទប។ កំណត់សម្គាល់ជាដំបូងរបស់ការរលាកកន្ទប គឺជាធម្មតាឡើងក្រហម ឬឡើងកន្ទួលតូចៗក្រោមពោះ, គូទ, កន្លែងបត់ជើងតូច, និងក្រលៀនដែលបានជាប់ជាតិសើម ឬកន្ទបដែលប្រឡាក់។ ការរលាកកន្ទបបែបនេះធម្មតាមិនជាធំដុំទេ ហើយជាញឹកញាប់វានឹងបាត់ក្នុងរយៈពេលបី ឬបួនថ្ងៃដោយសារការថែទាំដោយល្អ ត្រឹមត្រូវ។

ដើម្បីបន្ថយកុំឲ្យកូនតូចរបស់លោកអ្នកកើតការរលាកកន្ទប សូមធ្វើតាមរបៀបខាងក្រោមនេះរាល់ពេលដែលលោកអ្នកផ្លាស់កន្ទបឲ្យកូន:

- ផ្លាស់កន្ទបទទឹកភ្លាមតាមលទ្ធភាពដែលអាច បន្ទាប់ពីកូននោះបត់ជើងធំជូតកន្លែងដែលស្លៀកកន្ទបប្រើក្រណាត់ទន់ និងទឹករាល់ពេលដែលកូននោះបត់ជើងធំរួច។
- ផ្លាស់កន្ទបទទឹកចេញឲ្យបានញឹកញាប់ ដើម្បីបន្ថយកុំឲ្យស្បែកវាសើមពេក។
- អនុញ្ញាតឲ្យគូទកូននោះត្រូវខ្យល់ខ្លះនៅពេលណាដែលធ្វើទៅបាន បើអាចជៀសវាងបានគួរកុំប្រើខោដែលធ្វើពីកៅស៊ូ។
- ការប្រើក្រណាត់សម្រាប់ជូតគូទដែលលក់នៅតាមផ្សារអាចនឹងធ្វើឲ្យរលាកកាន់តែខ្លាំង។

មានហេតុដែលបណ្ដាលពីរយ៉ាង ជាធម្មតានៃការរលាកកន្ទបនេះ ហ្វាម៉ាស៊ីរបស់លោកអ្នកបានពិនិត្យពីជំពូកដែលកូនលោកអ្នកងាយនឹងរលាក ហើយណែនាំលោកអ្នកពីរបៀបព្យាបាល។

_______ ការរលាករបស់កូនលោកអ្នក ជាធម្មតាកើតឡើងដោយការក្រហាយនៅលើស្បែក ដែលបណ្ដាលមកពីកន្ទប សូមធ្វើតាមគ្រប់ទាំងការណែនាំសម្រាប់ការរលាកកន្ទបខាងលើនេះ ហើយប្រើថ្នាំក្រមួនវីតាមីនអេ និងឌី។ ថ្នាំនេះអាចជួយបន្ថយភាពស្ងួត និងក្រហាយនៅលើស្បែកដាក់បន្តិចនៅលើកន្លែងស្បែកដែលរលាក ៣-៤ដងក្នុងមួយថ្ងៃ។

_______ ការរលាកកន្ទបរបស់កូនលោកអ្នក ធម្មតាកើតឡើងដោយសារជាតិដំបែ ឬជាតិដុះផ្សិត ការនេះកើតឡើងជាញឹកញាប់នៅពេលដែលកូនក្មេងនោះទទួលថ្នាំអង់ទីប៊ីយោទីក។ បើសិនជាការរលាកនេះកើតមានពីរបីថ្ងៃហើយ សូមប្រើក្លូទ្រីម៉ាសូល ១%លាបនៅកន្លែងដែលស្លៀកកន្ទបនោះ ៣ដងក្នុងមួយថ្ងៃ។

សំរាប់ការរលាកណាក៏ដោយ: បើសិនជាការរលាកនោះមិនបានគ្រាន់បើក្នុងរយៈពេល៣ថ្ងៃទេ ឬក៏បើសិនជាកូនរបស់លោកអ្នកចាប់ឡើងពងបែក, របកស្បែក, ក្រៀម, មានខ្ទុះ, ឡើងដូចមុន, ឬក៏ដំបៅ- ពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់លោកអ្នក។

បើសិនជាលោកអ្នកមានសំនួរអ្វី អំពីថ្នាំរបស់លោកអ្នក សូមទូរស័ព្ទទៅគ្លីនិកតាមលេខ